# មេរៀនទី ១២៦: ពេត្រុសពន្យល់ពីការជឿលើព្រះយេស៊ូវ

## ១ ពេត្រុស ១:៣-៩

**គោលបំណង៖** ព្រះយេស៊ូវឱ្យយើងកើតជាថ្មី។

**ខគម្ពីរចងចាំ៖ ២ កូរិនថូស ៥:១៧** *“បានជាបើអ្នកណានៅក្នុងព្រះគ្រីស្ទនោះឈ្មោះថាបានកើតជាថ្មី ហើយអស់ទាំងសេចក្តីចាស់បានកន្លងបាត់ទៅ មើលគ្រប់ទាំងអស់បានត្រឡប់ជាថ្មីវិញ។”*

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

ជ័យជំនះរបស់ព្រះយេស៊ូវលើសេចក្តីស្លាប់ បាននាំមកនូវសេចក្តីសង្ឃឹមដែលមិនអាចផ្លាស់ប្តូរបានមកឱ្យពួកយើង។ តើសេចក្តីសង្ឃឹមលើព្រះយេស៊ូវមានឥទ្ធិពលយ៉ាងណាចំពោះសុភមង្គល ឬភាពមិនសប្បាយចិត្តរបស់អ្នក? តើវាអាចទៅរួចដែរឬទេដែលយើងមានសង្ឃឹមហើយ ប៉ុន្តែមិនអាចសប្បាយចិត្តបាន? ការដែលមានសេចក្តីសង្ឃឹមមិនមែនមានន័យថា យើងនឹងមានជីវិតសប្បាយរីករាយរហូតនោះទេ ប៉ុន្តែវាជួយឱ្យយើងអាចផ្លាស់ប្តូរការគិតនៅក្នុងជីវិតបាន។ សូមឱ្យទ្រង់បានបង្ហាញអ្នកពីរបៀបដែលអ្នកឆ្លុះបញ្ចាំងពីសេក្តីសង្ឃឹមរបស់អ្នកចំពោះព្រះយេស៊ូវនៅក្នុងជីវិត? សូមអរព្រះគុណទ្រង់សម្រាប់ការស្តារព្រលឹងរបស់យើងឡើងវិញ ដែលបានផ្តល់ឱ្យយើងនូវអំណរដ៏ពិត និងប្រទានឱ្យយើងនូវសេចក្តីសង្ឃឹមជារៀងរហូតផងដែរ។

**ចំរៀង៖** ១. គឺជាការល្អដែលសរសើរព្រះ ២. Good News Club ៣. Good News

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**៣. ល្បែងកំសាន្ត « ប្តូរអាវរបស់អ្នក»**

**សម្ភារៈដែលត្រូវការ៖** អាវយឺតធំពីរ ឬបី




១. ចែកកុមារជាពីរឬ បីក្រុម
២. ឲ្យកុមារឈរជាជួរ ហើយជ្រើសរើសមេក្រុមម្នាក់មួយ
៣. គ្រូនឹងឲ្យអាវយឺតធំមួយទៅមេក្រុមនីមួយៗ ហើយមេក្រុមត្រូវពាក់អាវនោះ
៤. នៅពេលដែលគ្រូរាប់ ១ ២ ៣ មេក្រុមត្រូវចាប់ផ្តើមដោះអាវយឺតនោះ ហើយឲ្យទៅកុមារបន្ទាប់។ ឲ្យកុមារបន្ទាប់បន្តពាក់ និងដោះអាវនោះ រហូតដល់កុមារចុងក្រោយ។
៥. ក្រុមណាដែលអាចប្តូរអាវបានលឿនជាងគេក្រុមនោះជាអ្នកឈ្នះ។
៦. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា ក៏ដូចជាការដែលប្តូរអាវរបស់យើងអីចឹងដែរ ពួកយើងគឺចង់ផ្លាស់ប្តូរដួងចិត្តរបស់យើងឲ្យទទួលជឿព្រះយេស៊ូវរបស់យើងវិញម្តង។

**៤. ការណែនាំមេរៀន**

តើមានប្អូនប៉ុន្មាននាក់ស្គាល់សត្វដង្កូវខ្លះ? ដង្កូវគឺអាចផ្លាស់ប្តូរខ្លួនទៅជាមេអំបៅដ៏ស្រស់ស្អាតបាន ការកើតជាថ្មី

ប្រៀបបីដូចជាយើងបានផ្លាស់ប្តូរដួងចិត្តដ៏អាក្រក់របស់ពួកយើង ទៅជាដួងចិត្តថ្មីស្រស់ស្អាតដូចមេអំបៅតាម-រយៈការទទួលជឿព្រះយេស៊ូវ។ ក៏ដូចគ្នាដែរថ្ងៃនេះ យើងនឹងរៀនអំពីការកើតជាថ្មីនៅក្នុងព្រះគ្រីស្ទ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ព្រះយេស៊ូវបានឱ្យជីវិតថ្មីមួយដល់អស់អ្នកណាដែលជឿដល់ទ្រង់។ ព្រះយេស៊ូវអាចធ្វើការនេះបានដោយព្រោះទ្រង់ជាព្រះ ហើយទ្រង់មានអំណាចលើសេចក្តីស្លាប់។ ព្រះយេស៊ូវបានសុគតរួចមានព្រះជន្មរស់ឡើងវិញ ហើយទ្រង់មានព្រះជន្មរស់រហូតដល់សព្វថ្ងៃ។

នៅពេលដែលយើងនិយាយថាព្រះយេស៊ូវបានផ្តល់ជីវិតថ្មីដល់យើង គឺមានន័យថាទ្រង់បានសង្គ្រោះយើងពីអំពើបាប។ ទ្រង់បានអត់ទោស និងលាងជំរះអំពើបាបរបស់យើង ព្រមទាំងធ្វើឱ្យយើងក្លាយជាមនុស្សថ្មីម្នាក់ថែមទៀតផង។ ព្រះគម្ពីរបានប្រាប់យើងថា យើងមិនត្រូវការធ្វើអ្វីដើម្បីឱ្យយើងអាចទទួលនូវជីវិតថ្មីពីព្រះនោះទេ។ ព្រះប្រទានឱ្យយើងនូវជីវិតថ្មី នៅពេលដែលយើងជឿលើព្រះយេស៊ូវ នោះជាការជឿមួយដែលយើងហៅថា សេចក្តីជំនឿ។ យើងត្រូវតែជឿថានៅពេលដែលយើងជាមនុស្សមានបាប ព្រះយេស៊ូវបានសុគតនៅលើឈើឆ្កាងជំនួសយើង ហើយទ្រង់ក៏បានដកយកអំពើបាបគ្រប់យ៉ាងចេញពីយើងផងដែរ។ ក្រោយមកព្រះយេស៊ូវបានយកឈ្នះលើសេចក្តីស្លាប់ ហើយទ្រង់មានព្រះជន្មរស់ឡើងវិញ ដូច្នេះហើយទើបទ្រង់អាចឱ្យយើងរាល់គ្នានូវជីវិតអស់កល្បនៅឋានសួគ៌បាន! ទោះជាយ៉ាងណាក៏ដោយព្រះយេស៊ូវតែងតែគង់ជាមួយ និងតម្រង់ផ្លូវយើង ហើយជួយយើងឱ្យជ្រើសរើសផ្លូវដែលត្រឹមត្រូវ ដើម្បីក្លាយជាកូនប្រុសស្រីរបស់ព្រះអង្គ។

ពាក្យថាព្រះគុណ មានន័យថាគឺជាអ្វីមួយដែលព្រះបានប្រទានឱ្យយើង បើទោះបីជាយើងមិនស័ក្តសមនឹងទទួលវាក៏ដោយ នេះគឺដោយព្រោះទ្រង់ស្រឡាញ់យើង។ ការកើតជាថ្មី និងជីវិតថ្មីនៅក្នុងព្រះយេស៊ូវគឺប្រទានមកយើងតាមរយៈព្រះគុណ។ យើងមិនស័ក្តសមនឹងទទួលព្រះគុណនោះទេ ប៉ុន្តែព្រះបានប្រទានឱ្យយើងនៅពេលដែលយើងជឿទ្រង់ ដោយព្រោះទ្រង់ស្រឡាញ់យើង។

នៅពេលដែលយើងទទួលបាននូវការកើតជាថ្មីតាមរយៈសេចក្តីជំនឿនៅក្នុងព្រះយេស៊ូវ យើងបានក្លាយជាផ្នែកមួយនៃគ្រួសាររបស់ព្រះ ហើយយើងទទួលបានអំណោយទាន និងអភ័យឯកសិទ្ធិដ៏អស្ចារ្យជាច្រើន។ យើងដឹងថា ពេលមានព្រះយេស៊ូវយើងនឹងមានសេចក្តីសង្ឃឹមដ៏ពិតប្រាកដសម្រាប់អនាគតរបស់យើង។ យើងក៏ដឹងផងដែរថា យើងនឹងទទួលនូវមរតកដែលមិនអាចបំផ្លាញបាន ហើយយើងដឹងថាអំណាចរបស់ព្រះបានការពារយើង យើងនឹងទទួលបាននូវអំណរដ៏អស្ចារ្យ យើងនឹងអាចទៅនគរស្ថានសួគ៌ដើម្បីរស់នៅជាមួយព្រះជារៀងរហូត!

តើអ្នកមិនសប្បាយចិត្តទេឬដែលអ្នកបានក្លាយជាគ្រួសារនៃព្រះ តាមរយៈសេចក្តីជំនឿដែលយើងមានចំពោះទ្រង់។ សរសើរតម្កើងព្រះនាមព្រះយេស៊ូវដែលទ្រង់បានប្រទាននូវជីវិតថ្មីដល់យើង!

## ៦. សំនួរពិភាក្សា

១. តើព្រះយេស៊ូវផ្តល់ជីវិតថ្មីដល់យើងដោយរបៀបណា?

*ដោយព្រោះទ្រង់ជាព្រះ ហើយទ្រង់មានអំណាចលើសេចក្តីស្លាប់*

២.តើអ្នកត្រូវធ្វើអ្វីដើម្បីឱ្យអ្នកមានសេចក្តីជំនឿទៅលើព្រះបាន? *ជឿថាព្រះយេស៊ូវបានស្លាប់ ជំនួសអំពើបាបរបស់យើង ហើយទ្រង់បានយកឈ្នះលើសេចក្តីស្លាប់ ដើម្បីឱ្យយើងមានជីវិតអស់កល្ប ហើយទ្រង់គង់ជាមួយយើងរហូតដល់សព្វថ្ងៃ*

៣. តើពាក្យថាព្រះគុណមានន័យដូចម្តេច? *ព្រះប្រទានឱ្យយើងនូវអ្វីដែលយើងមិនសមនឹងទទួល*

៤.តើព្រះគុណអ្វីដែលព្រះបានប្រទានដល់យើង?*ការកើតជាថ្មីនៅក្នុងព្រះយេស៊ូវពេលដែលយើងជឿលើទ្រង់*

៥. តើអ្នកសប្បាយចិត្តដែរឬទេនៅពេលដែលអ្នកបានក្លាយជាសមាជិកគ្រួសាររបស់ព្រះ?*សូមឱ្យកុមារឆ្លើយ*

## ៧. ល្បែងកំសាន្ត «រាំជញ្ជូនប៉េងប៉ោង»

**សម្ភារៈដែលត្រូវការ៖** ប៉េងប៉ោង




១. ឲ្យកុមារចាប់ដៃគូរពីរៗនាក់

២. ក្រុមនីមួយៗត្រូវយកប៉េងប៉ោងម្នាក់មួយ

៣. ចំណុចចាប់ផ្តើម ពួកគេត្រូវរាំឲ្យទៅដល់ចុងម្ខាងនៃថ្នាក់រៀនដោយរាំផង និងប្រើក្បាលរបស់ពួកគេព្យាយាមទប់ប៉េងបោងមិនឲ្យធ្លាក់ផង។(គ្រូត្រូវចាក់ភ្លេងឲ្យកុមាររាំ)

៤. ប្រសិនបើពួកគេធ្វើឲ្យបេងប៉ោងធ្លាក់នោះពួកគេនឹងចាញ់ល្បែងនេះ។

៥. ក្រុមណាដែលអាចរាំត្រឡប់មកដល់ទីចាប់ផ្តើមវិញបានមុនគេ ដោយមិនឲ្យជ្រុះប៉េងប៉ោង នោះក្រុមរបស់ពួកគេជាអ្នកឈ្នះល្បែងនេះ ហើយក្រុមគេនឹងទទួលបានរង្វាន់។

៦. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ប៉េងប៉ោងមិនអាចត្រឡប់មកកាន់ទីចាប់ផ្តើមវិញ ដោយមិនមានកុមារបាននោះទេ។ ក៏ដូចគ្នានេះដែរ ពួកយើងគឺមិនអាចទទួលបានការសង្គ្រោះ និងទទួលបានជីវិតថ្មីដោយមិនមានព្រះយេស៊ូវនោះទេ។

## ៨. ខគម្ពីរចងចាំ ២ កូរិនថូស ៥:១៧

## ៩. ហត្ថកម្ម «ព្រះយេស៊ូវបានផ្តល់ជីវិតថ្មីសម្រាប់យើង»

**សម្ភារៈដែលត្រូវការ៖** បោះពុម្ពក្រដាសហត្ថកម្មនៅទំព័រខាងក្រោម កូល័រទៀន ការបិត កន្ត្រៃ និងខ្មៅដៃ



១. ចែកក្រដាសហត្ថកម្មឱ្យកុមារម្នាក់១សន្លឹក រួចឱ្យពួកគេផាត់ពណ៌ និងតុបតែងនៅខាងក្នុងនិងខាងក្រៅរូបបេះដូង

២. ឱ្យកុមារកាត់រូបបេះដូង និងខគម្ពីរចងចាំចេញ រួចឱ្យពួកគេបិតខគម្ពីរចងចាំនៅក្នុងបេះដូងនោះ។

៣. ឱ្យកុមារអានខគម្ពីរចងចាំទាំងអស់គ្នា និងរំឭកពួកគេថា ព្រះយេស៊ូវបានផ្លាស់ប្រែពួកគេតាមរយៈសេចក្តីជំនឿរបស់ពួកគេចំពោះព្រះអង្គ។

## ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

## ១១. អធិស្ឋាន *(សូមនាំកុមារអធិស្ឋានបិទ)*

# ព្រះយេស៊ូវបានផ្តល់ជីវិតថ្មីសម្រាប់យើង



**២ កូរិនថូស ៥:១៧** “បានជាបើ
អ្នកណានៅក្នុងព្រះគ្រីស្ទនោះ
ឈ្មោះថាបានកើតជាថ្មី ហើយ
អស់ទាំងសេចក្តីចាស់បានកន្លង
បាត់ទៅមើលគ្រប់ទាំងអស់បាន
ត្រឡប់ជាថ្មីវិញ។”

**២ កូរិនថូស ៥:១៧** “បានជាបើ
អ្នកណានៅក្នុងព្រះគ្រីស្ទនោះ
ឈ្មោះថាបានកើតជាថ្មី ហើយ
អស់ទាំងសេចក្តីចាស់បានកន្លង
បាត់ទៅមើលគ្រប់ទាំងអស់បាន
ត្រឡប់ជាថ្មីវិញ។”

